# កិច្ចការបញ្ចប់មេរៀនទី៣៨-ពណ៌នាអំពីព្រឹត្តិការណ៍

**អំណាន:** ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។

កាលពីថ្ងៃអាទិត្យមុន មានគ្រោះថ្នាក់ចរាចរណ៍កើតឡើងត្រង់ចំណុចផ្លូវកោងក្បែរសាលារៀនមួយ ។

មុនពេលកើតហេតុគេឃើញមានភ្លៀងធ្លាក់យ៉ាងខ្លាំង ហើយមានបុរសម្នាក់បើកបរម៉ូតូពីលិចទៅកើតក្នុងល្បឿនលឿន។ លុះទៅដល់ចំណុចផ្លូវកោង ហើយរអិលផង ម៉ូតូក៏ជ្រុលចង្កូតធ្លាក់ពីលើផ្លូវ រួចទៅបុកនឹងដើមឈើ។ អ្នករស់នៅក្បែរនោះ រួមទាំងអ្នកធ្វើដំណើរបានស្ទុះទៅមើលហេតុការណ៍នេះ។ ក្រោតពេលកើតហេតុ គេឃើញម៉ូតូត្រូវខូចខាតទាំងស្រុង រីឯអ្នកបើកបរវិញ មានឈាមពេញខ្លួនដោយរងរបួសធ្ងន់ដេកសន្លប់ស្តូកស្តឹង។ មួយសន្ទុះក្រោយមក គេឃើញមានកម្លាំងសមត្ថកិច្ចមកជួយធ្វើអន្តរាយគមន៍យកអ្នករបួសទៅកាន់មន្ទីរពេទ្យ ។

ដូចច្នេះយើងគ្រប់គ្នា ត្រូវប្រុងប្រយ័ត្នជានិច្ច និងគោរពច្បាប់ចរាចរណ៍ឱ្យបានខ្ជាប់ខ្ជួននៅពេលធ្វើដំណើរ ។

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើអត្ថបទនេះពណ៌នាអំពីអ្វី ?

☐ ក. សមត្ថកិច្ចចាប់ជនល្មើស　　☐ ខ. មេឃមានភ្លៀងធ្លាក់ខ្លាំង

☐ គ. ផ្លូវរអិលខ្លាំង　　☐ ឃ. គ្រោះថ្នាក់ចរាចរណ៍

២. តើអត្ថបទនេះមានប៉ុន្មានកថាខណ្ឌ ?

☐ ក. មានមួយកថាខណ្ឌ　　☐ ខ. មានពីរកថាខណ្ឌ

☐ គ. មានបីកថាខណ្ឌ　　☐ ឃ. មានបួនកថាខណ្ឌ

៣. តើតែងសេចក្តីមានប៉ុន្មានផ្នែក ?

☐ ក. មានប្រាំពីរផ្នែក　　☐ ខ. មានបីផ្នែក

☐ គ. មានបួនផ្នែក　　☐ ឃ. មានប្រាំផ្នែក

LIVEWORKSHEETS

៤. តើសេចក្តីផ្តើមនៃអត្ថបទនិយាយពីអ្វី ?

☐ ក. ពេលវេលា ☐ ខ. ទីកន្លែង

☐ គ. ព្រឹត្តិការណ៍ ☐ ឃ. ពេលវេលា ទីកន្លែង ព្រឹត្តិការណ៍

៥. តើតួសេចក្តីនៃអត្ថបទនិយាយពីអ្វី ?

☐ ក. មុនពេលកើតហេតុ ☐ ខ. ពេលកើតហេតុ

☐ គ. ក្រោយពេលកើតហេតុ ☐ ឃ. មុនពេល ពេល ក្រោយពេលកើតហេតុ

៦. តើសេចក្តីបញ្ចប់នៃអត្ថបទនិយាយពីអ្វី ?

☐ ក. ចំណាប់អារម្មណ៍ ☐ ខ. ជូនពរ

☐ គ. សេចក្តីថ្លែងអំណរគុណ ☐ ឃ. ការប្តេជ្ញាចិត្ត

៧. ចូររកបដិសព្ទនឹងពាក្យ " ប្រយ័ត្ន " ។

☐ ក. យឺតៗ ☐ ខ. លឿន

☐ គ. ប្រញាប់ ☐ ឃ. ប្រហែស

៨. ចូររកវេវចនសព្ទនឹងពាក្យ " ខ្លួន " ។

☐ ក. កាយា ☐ ខ. ចង្កេះ

☐ គ. ជើង ☐ ឃ. ពោះ

➢ សំណេរ

១. ចូរពន្យល់ពាក្យ " ចរាចរណ៍ ប្រយ័ត្ន " ខាងក្រោមឱ្យបានត្រឹមត្រូវ ។

➢ ចរាចរណ៍ ( ) ..........................................................................................

➢ ប្រយ័ត្ន ( ) ..........................................................................................

២. ចូររៀបពាក្យ ឬកន្សោមពាក្យក្នុងប្រអប់ឱ្យបានជាល្បះត្រឹមត្រូវ ។

ក.

| | | | | | |
|---|---|---|---|---|---|
| យើងត្រូវ | បើកបរ ។ | ប្រុងប្រយ័ត្ន | ការ | នៅក្នុង | ចេះ |

..........................................................................................

ខ.

| | | | | |
|---|---|---|---|---|
| ពាក់មួក | ការពារ | ក្នុងពេល | ធ្វើដំណើរ ។ | សុវត្ថិភាព |

..........................................................................................

LIVEWORKSHEETS

៣. ចូរជ្រើសរើសសំណួរខាងក្រោមទៅបំពេញផ្នែកនីមួយៗ ឱ្យបានត្រឹមត្រូវ ។

- តើអ្នកមានចំណាប់អារម្មណ៍ដូចម្តេចចំពោះហេតុការណ៍នេះ ?
- តើព្រឹត្តិការណ៍នេះកើតឡើងនៅពេលណា? កន្លែងណា ?
- តើវាបង្កឡើងដោយសារអ្វី?
- ក្រោយពេលកើតហេតុ តើមានអ្វីកើតឡើង ?
- នៅពេលកើតហេតុ តើមានអ្វីកើតឡើង ?

ក. សេចក្តីផ្តើម

..........................................................................................................................................

..........................................................................................................................................

ខ. តួសេចក្តី

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

គ. សេចក្តីបញ្ចប់

..........................................................................................................................................

..........................................................................................................................................

LIVEWORKSHEETS